# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ២១

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

v: 09

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្តីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ២១

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

# បញ្ជីរឿង

ទំព័រ


១— អារ្យធម៌នៃស្រុកខ្មែរ, ស្រង់យកអំពីរឿងមួយ ដែលលោកសឺដែសបានរៀបរៀង (តពីលេខ ១៩ មក) . . . . . . . . . . . . . . . . . . . . ៣

២— លក្ខណភូមិសាស្ត្រស្រុកខ្មែរ . . . . . . . . . . . . . . . . . . ៦

៣— អំពីរឿងរាមកេរ្តិ៍របស់សាមញ្ញជននៅប្រទេសឥណ្ឌៀ . . . . . . . . . . ៩

៤— ជម្ងឺចំពួកខ្វះ របស់ជីវកកោមារភត្យ (តមក) . . . . . . . . . . . . ១៥

៥— វិធីធ្វើបម្ការប្បារដំណាំ (តនឹងចប់) . . . . . . . . . . . . . . . . . ១៨

៦— រឿងព្រេងខ្មែរ "រឿងឈ្មួញម្នាក់" . . . . . . . . . . . . . . . . . . ២៥


## រូបក្រៅរឿង


ក្លូកប្រាសាទអង្គរ — នេះព្រះពុទ្ធរូបសម័យអង្គរ . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


Pages

1° Civilisation du Cambodge. Extrait d'un article rédigé par Monsieur Cœdès (suite du n° 19 de la revue)............ 3

2° Caractères géographiques du Cambodge.................. 6

3° Au sujet d'une version populaire du Rāmāyaṇa aux Indes.... 9

4° Quelques maladies contagieuses, par Jivaka Komārabhatya (suite)........................................ 14

5° La culture maraîchère et les jardins fruitiers, par un Néak-Srè (suite et fin).................................... 18

6° Conte populaire Cambodgien inédit : " Récit d'un marchand "............................ 25

HORS - TEXTE

Groupe d'Angkor — Statue du Bouddha. Époque d'Angkor. 1



ពួកប្រាសាទអង្គរ — នេះព្រះពុទ្ធរូបសម័យអង្គរ

# អារ្យធម៌ខ្មែរ

របស់លោកសឺដែស

បណ្ដាក្សត្រខ្មែរមិនបានឈប់នៅត្រឹមសេចក្ដីប្រែប្រួលតាមសេចក្ដីប្រាជ្ញប្រាជ្ញាយដែលប្រទេសឥណ្ឌានាំផ្សាយចូលមកប៉ុណ្ណោះទេ ។ នៅខណៈដែលស្រុកទេសហិនហោចដោយសង្គ្រាមនឹងប្រទេសជិតខាង បណ្ដាក្សត្រកំពុងនឿយហត់ដោយកំណែនរបស់មហាក្សត្រដែលទ្រង់កសាងប្រាសាទតាំងអំពី ព.ស. ១៦៥០ មកនុ៎ះ ពួកខ្មែរស្ទើរតែនាំគ្នាលះបង់ការកសាងប្រាសាទ ហើយនាំគ្នាទៅជ្រកកោនក្រោមម្លប់ពុទ្ធសាសនាបែបលង្កា ឬដើម្បីបន្ធូយការទោសនៃគ្នាឯង ទើបពួកខ្មែរបញ្ចេញរស្មីនៃវប្បធម៌ហិណ្ឌូទៅឲ្យពួកថៃនៅតាមទន្លេមេគង្គនឹងទន្លេមេណាំវិញ ។

ពួកលាវក៏មានទំនងដូចជាពួកសៀមដែរ ជាពួកដែលមានពូជអំបូរស្រឡាយមកអំពីជនជាតិថៃដែលមាននៅពាសពេញប្រទេសឥណ្ឌូ-ស៊ីនកណ្ដាល តាំងអំពីទិសខាងកើតប្រទេសភូមាហូតដល់តំបន់ដែលមានដីខ្ពស់ៗនៅប្រទេសតុងកាំងនឹងសាយភាយទៅនៅតាមប្រទេសចិនខាងត្បូង ។

ឯពួកថៃដែលនៅក្នុងប្រទេសឥណ្ឌូស៊ីនសព្វថ្ងៃនេះជាពួកមកក្រោយគេទេ ហើយជាពួកដែលមានដើមកំណើតនៅក្នុងប្រទេសចិនខាងត្បូង ។

មុនពួកនេះចុះមកដីចិនខាងត្បូងនោះ ជនពួកនេះធ្លាប់មានដែនដីនៅក្នុងរង្វង់ប្រទេសចិនមកហើយ ប៉ុន្តែទឹងថាជនពួកនេះនៅតាមផ្លូវដើរគោកដែលនៅចន្លោះដីឥណ្ឌាទៅប្រទេសចិនក៏ថាពុំបាន តែទុកជាយ៉ាងណាក៏ដោយ តាមសេចក្ដីសង្កេតមើលរបៀបបែបផែនជនជាតិសៀមចំណុះនគរខ្មែរដែលគេបានធ្វើជារូបដំណាងទុកកាលពី ព.ស. ១៦៤៣ ដែលមានជាក្បាច់ចម្លាក់នៅប្រាសាទនគរវត្តនោះ គេអាចយល់ថាជាប្រជាជនជិតទៅខាងពួកជាតិមនុស្សនៅតាមភ្នំប្រទេសលាវខាងលើ នឹងប្រទេសតុងកាំងខាងលើ ។ ពួកថៃដែលចុះមកទិសខាងលិចនោះបានជួបប្រទះនឹងពួកមន ហើយជនពួកនេះហើយដែលជាពួកបានទទួលពុទ្ធសាសនាអំពីសីឡូន (កោះលង្កា) ហើយជនពួកនេះឯងដែលបានចម្លងយកបែបផែនច្បាប់ប្រពៃណីរបស់មន ។ នៅជំនាន់ទន្ទេរមេណាំ មុនដំបូងពួកថៃទទួលយកអារ្យធម៌អំពីពួកខ្មែរ ដោយពួកថៃស្ម័គ្រចិត្តនៅក្រោមសេចក្ដីត្រួតត្រារបស់ខ្មែរ កាលពី ព.ស. ១៥៥០ ។ លុះដល់ ព.ស. ១៧៩០ ទើបពួកក្សត្រថៃនៅសុខោថៃតាំងខ្លួនជាឥស្សរៈឯករាជ្យឡើង ។ ជនជាតិថៃពួកនេះបានទទួលយកបែបផែនវប្បធម៌របស់ហិណ្ឌូអំពីស្រុកខ្មែរទៅយ៉ាងជ្រាលជ្រៅទូលាយណាស់ ។

ទៅក្នុងដងទន្លេមេកុង ពួកលាវនៅក្រោមអំណាចស្រុកខ្មែរជាវេលាយូរ កាលពី ព.ស.១៧៩០ បានពង្រីកអាណាខេត្តចេញទៅរហូតដល់ដែនដីដែលជាទីក្រុងវៀងចន្ទន៍សព្វថ្ងៃនេះ ។ ប៉ុន្តែលុះមួយសតវត្សរ៍តមក ទើបមានពួកក្សត្រសៀមនៅក្រុងសុខោទៃត្រឡប់មានអំណាចត្រួតមកលើស្តេចអង្គរ ហើយកាត់យកដីចំណុះចាស់របស់ខ្មែរមកនៅក្រោមអំណាចខ្លួនរហូតដល់ដងទន្លេមេកុង ។

# អំពីលក្ខណៈភូមិសាស្ត្រ

## នៃប្រទេសកម្ពុជា

ទំហំទីដីនៃប្រទេសយើងនេះប្រមាណ ១៨១.០០០ គីឡូម៉ែត្រក្រឡា ចែកចេញជាផ្នែកៗ មាន ៣ ផ្នែកគឺ:

១) ប្រទេសនេះមានទន្លេធំ (មេគង្គ) ។

២) មានទន្លេសាប ។

៣) មានដងភ្នំជាច្រើននៅឈូងសមុទ្រសៀម ។

នៅតាមតំបន់មាត់ទន្លេមេគង្គ ប្រជាជនសឹងចិញ្ចឹមជីវិតដោយទឹកទន្លេ គឺរាល់តែឆ្នាំ តែងមានជោរជន់ឡើងហៀរហូរចូលទៅតាមព្រែក ហើយធ្វើបឹងនានាឲ្យពោរពេញទៅដោយទឹក ហើយនាំយកកកល្បាប់មកដាក់ក្រាលនៅទីនោះៗ លុះដល់ទឹកស្រកទៅ ទើបគេនាំគ្នាភ្ជួរដីធ្វើចំការដាំពោត, ដាំគប្បាស, ដាំថ្នាំ, ដាំបន្លែផ្សេងៗ ដល់ទឹកស្រកមែនទែន ទើបគេចាប់ដាំស្រូវនៅបាតបឹង ។ នៅចន្លោះទន្លេនិងបឹងនេះ ច្រើនតែឃើញមានផ្ទះសម្បែងអ្នកស្រុក ជាភូមិ ជាស្រុកនៅក្នុងទីកំបាំងស៊ុបទ្រុប ដោយដើមឈើផ្លែផ្សេងៗ ។ លុះចេញផុតពីមេគង្គទៅ ទីដីក៏កាន់តែច្រើន ជាដីល្អិត ថ្កក់ ហើយមានតែព្រៃស្រោង ឥតមនុស្សតែស្រែចំការ ។

ឯទន្លេសាបជាទីដ៏ធំជ្រៅមានសណ្ឋានជាបាតខ្ទះ ចំនួនប្រមាណ ៣.០០០ គីឡូម៉ែត្រក្រឡា នៅជាចន្លោះដងភ្នំក្រវាញ (ភ្នំខ្នោប) និងដងភ្នំដងរែក ៗ ទន្លេសាបនេះជាទីមានទឹកល្ហល្ហាបក្នុងខែទឹក ៗ ដល់ខែណ្យូរ៉មប្រើទឹកទន្លេមេគង្គក៏ស្រក. ឯទឹកទន្លេសាបក៏ហូរធ្លាក់មកទន្លេមេគង្គវិញ នៅឱកាសដែលទឹកទន្លេសាបស្រកនេះ មានពួកអ្នកនេសាទត្រីជាច្រើនប្រមាណ ៣០.០០០ នាក់ រួមទាំងជាតិយួន, ចិន, ចាមនិងសៀម នាំគ្នាធ្វើនេសាទកម្មក្នុងទន្លេសាប ។ ឯផលនៃការនេសាទកម្មនេះក្នុងមួយឆ្នាំ ៗ មានចំនួនត្រី ១០០.០០០ តោន ដែលគេនាំចេញទៅចំណាយប្រទេសក្រៅ ៗ ឯទិសខាងលិចជាទីដីស្រែស្រុកបាត់ដំបង ទិសខាងជើងជាទីព្រៃព្រឹក្សា នៅកណ្ដាលព្រៃនេះហើយដែលជាទីតាំងនៃបុរាណស្ថានអង្គរ ៗ

ស្រុកខ្មែរញែកចែកពីប្រទល់ដីស្រុកសៀម នៅទិសខាងជើងត្រង់ទួលខ្ពស់លើភ្នំខ្នោប ដែលមានកំពស់ ១៥០០ ម៉ែត្រពីទឹកសមុទ្រ នៅទិសខាងត្បូងនៅតាមជួរដងភ្នំដំរី ៗ ទួលខ្ពស់នេះស្ទើរតែគ្មានមនុស្សនៅគ្មាន មានតែពួកភ្នងបន្តិចបន្តួច ៗ ឯជើងជួរភ្នំនោះវិញជាច្រកទួលខ្យល់មូស្សុង ដែលបក់ជាត់ចូលមកក្នុងស្រុកខ្មែរ ហើយជាទីសំខាន់ខាងផ្លូវជំនួញដែលនាំចូលមកចំណាយនៅក្រុងភ្នំពេញនិងព្រៃនគរ បំពោះស្រុកខ្មែរគួរមានកំពង់ជំនួញដោយឡែកនៅទីឈូងសមុទ្រសៀមនេះ ៗ

ឯខ្យល់រដូវនៅស្រុកខ្មែរនេះទៀងទាត់ល្អណាស់ ដែលជារដូវ ៣ គឺ រដូវប្រាំង-រដូវក្តៅនិងរដូវទឹកឡើង ។

កំពង់ជំនួញក្រុងភ្នំពេញ នៅលើមាត់ពាមនៃដងទន្លេទាំង ៤ មកប្រសព្វគ្នា ហើយជាទីបញ្ចេញជំនួញស្រុកខ្មែរទៅកាន់ប្រទេសក្រៅៗ ។

# អំពីរឿងរាមកេរ្តិ៍របស់សាមញ្ញជន

(ប្រទេសឥណ្ឌា)

អ្នកមើលទស្សនាវដ្ដីរបស់យើងគង់តែបានជ្រាបច្បាស់ រឿងរាមាយណៈ ឬរឿងរាមកេរ្តិ៍ ដែលជាពាក្យកាព្យយ៉ាងសំបើមរបស់ឥណ្ឌាសម័យបុរាណ មានសេចក្ដីប្រែជាភាសាផ្សេងៗជាច្រើន មួយពួកជាភាសាសំស្ក្រឹត ក្រៅពីនេះជាភាសាផ្សេងៗនៅក្នុងឥណ្ឌា ។ កាព្យរាមកេរ្តិ៍នេះ បានផ្សាយចេញទៅក្នុងប្រទេសជ្វា ប្រទេសសៀមនិងប្រទេសខ្មែរ ។ យើងមិនបាច់រំឭករឿងក៏ដែលព្រះរាមនិងនាងសិតាជាភរិយាព្រមទាំងព្រះលក្ស្មណ៍ជាប្អូន ដែលគេនិរទេសបានសេចក្ដីលំបាកគោកយ៉ាកទុំនេ ដ្បិតជារឿងដែលអ្នកចេះរឿងរាមកេរ្តិ៍បានជ្រាបសព្វគ្រប់ហើយ ។ យើងស្រង់យកសេចក្ដីមួយ ត្រង់ដែលព្រះលក្ស្មណ៍គោងលះបង់ប្រពន្ធក្រមុំឈ្មោះឧម៌ិឡាទៅតាមព្រះរាម ។ មហាកវីឈ្មោះវ៉ាលមិកិ ជាអ្នកតែងរឿងរាមាយណៈជាភាសាសំស្ក្រឹតនោះ ដូចជាលោកទុករឿងនេះក្នុងទីងងឹតកំបាំង ត្រង់រឿងដែលពោលអំពីនាងឧម៌ិឡាជាភរិយាដ៏ស្មោះត្រង់របស់ព្រះលក្ស្មណ៍ ប៉ុន្តែក្នុងកាព្យរាមកេរ្តិ៍សាមញ្ញធម្មតាក្នុងដីឥណ្ឌាកណ្ដាលនោះ គេទុកដាក់នាងនេះជានាងឯកទីពីរ ។ នាងនេះទើបមិនមានគេស្គាល់ពីដើមមកដល់សព្វថ្ងៃនេះ ហើយរឿងរាមកេរ្តិ៍

របស់ប្រទេសដទៃក្រៅ ក៏មិនមានប្រទេសណាមួយនិយាយដល់រឿងនេះឡើយ ។ កាព្យរាមកេរ្តិ៍របស់ក្រស្តសាមញ្ញនេះ លោកឆេវ្រឿ សត្យាបិ ជាអ្នករើសប្រមូលមកហើយបោះពុម្ពជាភាសាអង់គ្លេសក្នុងទស្សនាវដ្ដីទំនើបថ្មីរបស់ឥណ្ឌា (Moderne revue) ប្រចាំខែអាព្រិលឆ្នាំ ១៩៤០ ។ ឯកំណាព្យរាមកេរ្តិ៍សាមញ្ញធម្មតានេះ គេបានបោះពុម្ពនៅលើកក្រោយបង្អស់ ។ មានច្បាប់កាព្យដែលគេបានបោះពុម្ពហើយក្នុងរោងពុម្ពផ្សេងៗដល់ ៣ លើក តែក្នុងច្បាប់នីមួយៗ ដែលមានសេចក្ដីប្លែកផ្សេងពីគ្នាខ្លះនោះមិនជាការសំខាន់ទេ ។

បទកាព្យខាងដើមនោះចាប់និយាយពីព្រះរាមគ្រងរាជសម្បត្តិនៅក្រុងអយុធ្យា កាលគង់លើរាជបល្ល័ង្កមានបរិវារៈចោមរោមគាល់បំរើ មានទាំងបងប្អូនរបស់លោកទាំងស្ដេចស្វាហនុមាន អង្គុយគាល់នៅទៀបព្រះបាទដោយគោរព ហើយសុគ្រីពអង្គុយគាល់បន្ទន់ខ្លួននៅមុខ ចំពោះព្រះភក្ត្រព្រះរាមដោយសេចក្ដីគោរពកោតខ្លាចដែរ ។ ឯពួកតន្ត្រីទាំងស្រីរបាំនៅស្ថានសួគ៌កំពុងលេងយ៉ាងកើននៅទីសន្និបាតនោះ បំណែកខាងពួកលោកអ្នកប្រាជ្ញក៏គិតជជែកប្រកែកគ្នាអំពីរឿងសាសនា និងបរមត្ថវិជ្ជា ហើយក៏មានភ្លៀងផ្កាបង្គុរចុះមកលើពួកអ្នកប្រាជ្ញអស់នោះ ។ ខណៈនោះ ព្រះនាងសីតាក៏លីលាចេញមកដោយដំណើរជាប្រក្រតី ទ្រង់ទតព្រះនេត្រឆ្មៀងទៅទីសន្និបាតនោះ រួចព្រះនាងបែរព្រះភក្ត្រឆ្ពោះទៅរក

ព្រះស្វាមី ក្នុងព្រះទ័យព្រះនាងមានសេចក្ដីព្រួយជាច្រើន ទើបព្រះនាង
លើកដៃប្រណម្យក្រាបបង្គំទូលសុំឲ្យព្រះរាមទ្រង់ព្រះសណ្ដាប់នឹងទ្រង់
ប្រទានឱកាសតាមសេចក្ដីសុំរបស់ព្រះនាង ទើបព្រះនាងក្រាបទូលព្រះ
រាមថា កាលព្រះលក្ខណ៍មានបំណងធ្វើដំណើរទៅជាមួយនឹងយើងកាល
ត្រូវនិរទេសនោះ ព្រះនាងឧម៉ិឡាក៏ចង់ទៅតាមដែរ តែព្រះលក្ខណ៍
បង្គាប់ឲ្យព្រះនាងនៅក្នុងរាជវាំង ។ តាំងពីថ្ងៃនោះមកព្រះនាងឧម៉ិឡាក៏
ផ្ទំលក់នៅជាយូរអង្វែង ។ ទើបព្រះនាងសីតាក្រាបទូលព្រះរាមសុំឲ្យ
បញ្ជូនព្រះលក្ខណ៍ទៅរកព្រះនាងឧម៉ិឡា ។ ព្រះរាមក៏ទ្រង់ប្រោសប្រ-
ទានតាមសេចក្ដីសុំរបស់ព្រះនាងសីតា ទើបទ្រង់បង្គាប់ឲ្យព្រះលក្ខណ៍
ទៅជួបនឹងមហេសី ព្រះលក្ខណ៍ក៏ទ្រង់យាងចេញពីប្រាសាទទ្រង់ចូល
ទៅកាន់ប្រាសាទព្រះនាងឧម៉ិឡា ទ្រង់ទតឃើញព្រះនាងផ្ទំលក់ ទើប
ទ្រង់ឡើងលើគ្រែបន្ទំទ្រង់ទតឃើញព្រះភក្ត្រមហេសីនៅស្រស់ញញឹម
ហើយទ្រង់មានបន្ទូលនឹងព្រះនាងៗឧម៉ិឡាទ្រង់បានឮសូរសំឡេងព្រះ
រាជស្វាមី ក៏ទ្រង់តើកព្រះស្នាតើពីបន្ទំ ប៉ុន្តែព្រះនាងចាំមិនបានថា អ្នក
ដែលមកដាស់នេះជាព្រះស្វាមី ទើបព្រះនាងគិតភ័យណាស់ ដ្បិតព្រះ
នាងស្មោះត្រង់នឹងព្រះស្វាមី ក្នុងខណៈដែលស្វាមីចេញចោលទៅ ព្រះ
នាងនឹកដល់រឿងនាងសីតាដែលរាពណ៍ចាប់យកទៅទាំងអំណាច ព្រះ
នាងគិតថា មនុស្សដែលមកនៅចំពោះមុខនេះ ក្រែងមកចាប់យកព្រះ

នាងទៅដូចជាកាលព្រះនាងសីតាទេដឹង ។ ឯព្រះលក្ស្មណ៍ក៏ភ្ញាក់ព្រះអង្គទើបឆ្លើយតបព្រះនាងឲ្យដឹងច្បាស់ថាជាប្ដីរបស់ព្រះនាង ជាប្អូនព្រះរាម ជាប្អូនថ្លៃព្រះនាងសីតា ហើយទ្រង់ស្ទុះទៅចាប់ក្រីប៉ីនទឹនចាក់សម្លាប់ព្រះអង្គឯង ប្រសិនបើព្រះនាងនៅតែមិនជឿថាជាអង្គព្រះលក្ស្មណ៍មែន ៗ ទើបព្រះនាងភ្ញាក់ព្រះអង្គក្នុងខណៈកើតឧប្បត្តិហេតុនេះឡើងទ្រង់ស្គាល់ច្បាស់ថាជាស្វាមីមែន ហើយព្រះនាងស្ទុះទៅឱបព្រះបាទព្រះលក្ស្មណ៍ ៗ ចាប់ព្រះនាងលើកឡើង ព្រះនាងទ្រង់ព្រះកន្សែងជាខ្លាំងទើបទ្រង់ល្ហួងលោមហើយទ្រង់ដំណាលរឿងរ៉ាវដែលកន្លងមកហើយឲ្យព្រះនាងស្ដាប់ ឃើញថាទាំងពីរព្រះអង្គគោងព្រាត់ប្រាសនិរាសគ្នាព្រាត់ប្ដីជាទីពេញចិត្តរបស់ភរិយា ៗ ជាទីស្នេហាក៏ប្រាសព្រាតប្ដី ឯព្រះលក្ស្មណ៍នឹងព្រះនាងឧម៉ិឡាក៏មិនរួចឲ្យផុតអំពីអំណាចរបស់កម្ម គោងតែអន្ទោលទៅតាមយថាកម្ម ៗ

តអំពីនោះមក ស្រីជាបរិវារក៏យកទឹកអប់នឹងក្រចេះខ្ទឹមចន្ទន៍ ទៅប្រាយឲ្យក្សត្រទាំងពីរអង្គស្រង់ទឹក ៗ ព្រះនាងឧម៉ិឡាទ្រង់ព្រះពស្ត្រថ្មីទ្រង់ប្រដាប់អង្គដោយពេជ្រនិលចិន្តាទាំងពួង ទ្រង់ឆោមលោមពណ៌ពណ្ណរាយដូចស្រីទេពធីតា រួចក្សត្រទាំងពីរព្រះអង្គទ្រង់យាងចូលកាន់មន្ទីរភោជនីយ៍ ដើម្បីទ្រង់សោយព្រះក្រយានៅទីនោះ ព្រះរាមទ្រង់អំណាចពណ្ណរាយដូចជាព្រះឥន្ទ្រ ទ្រង់ពក់ទាក់នឹងព្រះនាងឧម៉ិឡាដោយ

ព្រះឱស្ការយោទីតាប់ចិត្ត ព្រះនាងឧម៉ិឡាទ្រង់អៀនខ្មាសជ្រប់ព្រះភក្ត្រមិនចរចា ហើយព្រះនាងទៅគង់ជិតព្រះរាជស្វាមី ទ្រង់សេពសោយសប្បិយ៉ាងល្អព្រមទាំងនំផ្សេងៗ ដែលពួកបរិចារលើកមកថ្វាយ ជាមួយនឹងទឹកផោះគាស្រស់ ៗ រួចក្សត្រគ្រប់ៗអង្គនាំគ្នាទៅលាងព្រះហស្តក្នុងទឹកខ្ទេតគ្គា ហើយទ្រង់សោយព្រះស្រីដីលាងព្រះឱស្ឋ ៗ លុះព្រះនាងឧម៉ិឡានឹងព្រះលក្ស្មណ៍យាងចូលទៅក្នុងប្រាសាទវិញហើយ ទើបព្រះនាងទូលព្រះស្វាមីឲ្យទ្រង់ដំណាលរឿងរ៉ាវនាងសីតាឲ្យព្រះនាងស្តាប់ ទើបព្រះលក្ស្មណ៍ដំណាលរឿងរ៉ាវដែលកន្លងមកនោះសព្វគ្រប់ ហើយនិយាយពីរឿងសីតាត្រូវគេនាំទៅលង្កា ពីរឿងដែលព្រះរាមទៅតាមព្រះនាងសីតា ឲ្យហនុមានយកចិញ្ចៀនទៅថ្វាយនាងសីតា ពីរឿងហនុមានត្រឡប់មកវិញ ទាំងគួរគំនូនាងសីតាដែលជាប់ឃុំមុខគ្នាឲ្យអាណោចអាធម្មណាស់ ហើយទ្រង់ដំណាលពីរឿងគេពិសោធឲ្យនាងសីតាដើរចូលភ្លើង ហើយនាងចេញពីភ្លើងបានឥតមានរេះរោក ៗ

ក្នុងសេចក្តីតមកថា នាងឧម៉ិឡានឹងព្រះលក្ស្មណ៍ទាំងពីរព្រះអង្គបានទៅជាទេព្តាស្ថិតឰដ៏ស្ថានសួគ៌ តាំងអំពីនោះមកតែងតែគ្រប់គ្រងថែរក្សាពួកអ្នកចម្រៀងដែលច្រៀងកាព្យពមកេរ្តិ៍នេះ នឹងពួកអ្នកស្តាប់ពាក្យកាព្យនេះផង ៗ

តាមដែលយើងដឹងពាក្យកាព្យពមកេរ្តិ៍នេះ នៅស្រុកខ្មែរមិនមែនមានសេចក្តីដូចជាពាក្យកាព្យនេះឡើយ ៗ

## ៣– ការធ្វេសប្រហែសក្នុងការបៀមរបស់ទុកក្នុងមាត់

មានមនុស្សខ្លះចូលចិត្តបៀមអ្វីៗទុកក្នុងមាត់ បើជារបស់មិនស្អាត ក៏អាចនាំឲ្យមេជម្ងឺចូលទៅក្នុងមាត់ ឬរបស់ដែលបៀមរបូតចូលទៅក្នុងបំពង់កក៏មាន ដូចជាការបៀមដែកគោល ម្ជុលដេរ ម្ជុលខ្ទាស់ជាដើម ដល់វេលាក្អក កណ្តាះឬសើច ក៏អាចធ្វើឲ្យរបស់ដែលបៀមទុកក្នុងមាត់ របូតចូលទៅក្នុងបំពង់កបានដោយងាយ ក្រៅពីនេះ យើងគង់ធ្លាប់បានឮពួកអ្នកនេសាទត្រី ច្រើនតែមានគ្រោះថ្នាក់នឹងផ្លែសន្ទូចជាញឹកញយ ៗ

## ៤– ការធ្វេសប្រហែសរបស់មាតាបិតាឬពីលៀង

ក្មេងតូចៗជាច្រើនចូលចិត្តស្រវាចាប់អ្វីៗដាក់ទៅក្នុងមាត់ បើជាវត្ថុតូចៗឬទន់ ក៏លេបចូលទៅបានដោយស្រួល បើជារបស់រឹងដូចជាលុយសេនឬដុំក្រួសដុំថ្ម ក៏អាចទៅជាប់ណែនក្តន់នៅក្នុងបំពង់កមិនខាន ៗ

គ្រឿងស៊ីគ្រឿងផឹករបស់ក្មេងតោងតែប្រយ័ត្ននឹងចាត់ចែងតាមអាយុរបស់ក្មេង ក្មេងតូចៗមិនត្រូវឲ្យស៊ីរបស់រឹង ឬផ្លែឈើដែលមានគ្រាប់

ឡើយ ព្រោះអាចមានអន្តរាយបាន ដូចមានតួយ៉ាងនិយាយថា មានកូនចិនម្នាក់អាយុប្រមាណ ៣ ឆ្នាំ ម្ដាយឪពុកនាំវាទៅផ្ទះពេទ្យប្រាប់ថាវាដកដង្ហើមខ្លាស់ៗ យ៉ាងលំបាក មុខឡាត់ឡើងខៀវៗ គ្រូពេទ្យសួររឿងរ៉ាវមិនបានសេចក្ដីសោះ ក៏សន្និដ្ឋានថាប្រហែលវាកើតរោគខាន់ស្លាក់ តែពិនិត្យទៅមិនមានអាការរោគបែបនេះឡើយ ហើយពិនិត្យទៅទៀតឃើញថាវាកដង្ហើមខ្លាស់ៗ នៅចំណែកខាងលើ ទើបព្រមព្រៀងគ្នាថាតោងវះកក្មេងនោះជាប្រញាប់បន្ទាន់យូរទៅទៀតពុំបាន ខណៈដែលវះកនោះក្មេងក៏ក្អក ស្រាប់តែមានគ្រាប់ទៀបរបូតមកតាមមុខរបួស ១ គ្រាប់ ហើយក្មេងក៏ដកដង្ហើមបានស្រួលដូចធម្មតា ។ នេះជាតួយ៉ាងដែលមាតាបិតាធ្វេសប្រហែសបណ្ដោយឲ្យក្មេងបរិភោគរបស់មិនសមគួរតាមអាយុ និងធ្វេសប្រហែសត្រាតែមិនដឹងថាកូនខ្លួនកើតមិនស្រួលតាំងពីកាលណាបុស៊ីក្ដី ៗ

## ៥ — សេចក្ដីធ្វេសប្រហែសក្នុងការលេង

មានក្មេងជាច្រើន ចូលចិត្តទះតប់ខ្លួនពួកម៉ាកលេងខ្លាំងៗ បើប្អូនជាពួកម៉ាកនោះកំពុងស៊ីអ្វីឬបៀមអ្វីនៅក្នុងមាត់ ហើយភ្ញាក់ខ្លួនដងក៏អាចធ្វើរបស់ដែលបៀមទុកក្នុងមាត់នោះ ឲ្យចូលទៅក្នុងបំពង់កបានដោយងាយៗ មានក្មេងខ្លះចូលចិត្តបៀមអ្វីៗ ហើយរត់លេង បើដួលជាខ្លួនតែចំពប់ដួល

ក៏អាចធ្វើរបស់ដែលបៀមនោះឲ្យរបូតចូលទៅក្នុងបំពង់កបាន ឬវេលាស៊ីអាហារចំណីអ្វីៗត្រូវហាមប្រាមក្មេងកុំឲ្យរត់ស៊ីបណ្តើររត់លេងបណ្តើរសោះឡើយ ព្រោះអាចធ្វើឲ្យអាហារចំណីក្រឡុកចូលទៅក្នុងបំពង់កបានដោយមិនបានទំពាឲ្យល្អិតជាមុន ។

## វិធីការពារ

១ – អាហារចំណីសម្រាប់ក្មេង មនុស្សជម្ងឺ មនុស្សចាស់ មិនត្រូវឲ្យមានឆ្អឹងសត្វ ឆ្អឹងត្រី ផ្លែឈើមានគ្រាប់ ដូចគ្រាប់ឪឡឹក គ្រាប់ក្រូចជាដើម លាយច្របល់ផងទេ ។

២ – ការបរិភោគអាហារចំណីអ្វីផ្សេងៗ តោងតែប្រយ័ត្នកុំប្រញាប់ប្រញាល់ ត្រូវទំពាឲ្យល្អិតជាមុនសិនសឹមលេបចូលទៅ ។

៣ – និស្ស័យក្មេងដែលចូលចិត្តខាំដីស ឈើចាក់ធ្មេញ ដើមស្មៅ ដើមធូប កៅស៊ូ ។ ល ។ គួរហាមប្រាមឲ្យក្មេងឈប់លេង ព្រោះអាចធ្វើឲ្យវត្ថុអស់នោះរបូតចូលទៅក្នុងបំពង់កបាន ឬបើវត្ថុនោះមិនស្អាតផង ក៏អាចនាំឲ្យកើតរោគផ្សេងៗឡើងបាន ។

៤ – តោងខំបង្ហាត់ក្មេងកុំឲ្យបៀមអ្វីៗ លេងនៅក្នុងមាត់ ។

៥ – វេលាក្មេងបរិភោគអាហារចំណី ត្រូវហាមកុំឲ្យរត់ឬលោតតញ្ចេញលេងឲ្យសោះ ។

៦ – កុំបណ្ដោយឲ្យក្មេងតូចៗ ដេកនទៀលលេងនឹងក្ដារឬទឹងដ៏ឲ្យសោះ ។

៧ – របស់ដែលក្មេងលេង ដូចរូបតុក្កតាជាដើម តោងសង្កេតមើលឲ្យល្អ ក្រែងក្មេងកាច់ខ្ទេះក្អែកឬបេះឡេវយកមកបៀមលេង ។

៨ – ក្មេងដែលមានអាយុតិចជាង ២ ខួប កុំឲ្យស៊ីផ្លែសណ្ដែកផ្សេងៗ គ្រាប់ឪឡឹក ផ្លែទៀប តែលាវ ឬនំក្រៀមក្រោះតូចៗ ព្រោះក្មេងមិនសូវចូលចិត្តទំពារទេ ច្រើនតែលេបនាំឲ្យស្លក់កដោយងាយបាន ។

៩ – វេលាតាក្មេង ឬប្រលែងនឹងក្មេង តោងប្រយ័ត្នកុំឲ្យកំពាញបេះយកឡេវឬម្ជុលខ្ទាស់ទៅបៀមលេងឡើយសោះ ។

១០ – ផ្ទះដែលមានក្មេងច្រើនត្រូវប្រយ័ត្នម្ជុលខ្ទាស់បិទមុខ តោងទុកដាក់ឲ្យផុតពីដៃក្មេង ទឹងខ្ទាស់ឲ្យបិទមុខជានិច្ច កុំឲ្យមុខរហាឲ្យសោះ ព្រោះអាចធ្វើឲ្យមុតក្មេង ឬក្មេងរើសយកមកបៀមលេងនឹងមានអន្ដរាយដល់ខ្លួនក្មេងជាច្រើន បើបានបិទមុខជិត អន្ដរាយក៏មានតិច ។

១១ – អ្នកដែលដាក់ធ្មេញឬមានធ្មេញរង្គើខ្លាំង តោងតែប្រយ័ត្នជានិច្ច កុំឲ្យធូរពេកឬរង្គោះរង្គើ ព្រោះក្រែងរបូតធ្លាក់ចូលទៅក្នុងបំពង់កបាន ។

(មានត)

# វិធីធ្វើចំការច្បារដំណាំ

(តមកនឹងចប់)

៥ — វិធីជ្រើសរើសតែពូជដំណាំល្អៗយកមកដាំ – ពូជដំណាំដែលត្រូវដាំដោយគ្រាប់ឬដោយផ្លែ ក៏ត្រូវរើសគ្រាប់ឬផ្លែល្អៗឥតពេកឬមានស្អុយខូចត្រង់កន្លែងណា ហើយត្រូវរើសយកពីដើមឈើដែលមានផ្លែស្កុក មានរសជាតិល្អមកដាំ បើផ្កាំមែកដាំ ក៏គួររើសផ្កាំតែមែកល្អៗដែរ ៗ មួយវិញទៀត មែកដែលផ្កាំទុកពេលយូរពេកទាល់តែងាប់ឫសទៅវិញខ្លះនោះមិនគួរយកទៅដាំទេ ព្រោះអាចនាំឲ្យក្របានផ្លែឬមានចួនកាលមិនផ្លែសោះក៏មាន ៗ

៦ — រដូវដែលត្រូវដាំ – គួរចាប់ដាំដើមឈើក្នុងរដូវភ្លៀងល្អជាងដាំក្នុងរដូវឯទៀត ព្រោះមិនបាច់លំបាកស្រោចទឹកខ្លាំងពេក លុះដល់រដូវប្រាំងដើមឈើល្មមចាក់ឫសដុះមែកបែកធាងល្មមទប់ទល់នឹងកំដៅថ្ងៃបានមិនសូវអន្តរាយដល់ទៅងាប់ដើមដោយកំដៅថ្ងៃ ៗ

៧ — វិធីជីករណ្ដៅ – ការដាំដើមឈើឲ្យឆាប់បានដុះលូតលាស់ល្អត្រូវតែជីករណ្ដៅដាំឲ្យជ្រៅហើយធំ បើជាទីដីស្អិតរឹងផងត្រូវជីកឲ្យជ្រៅនឹងធំមានជម្រៅប្រមាណ ២ ហត្ថ បើជាទីដីរបាយឲ្យមានទំហំនឹងជម្រៅត្រឹម ១ ហត្ថកន្លះក៏ល្មមបង្ការដើមឲ្យតាំងនៅត្រង់ទីនឹងជាដរាបល្អមើល មុន

ជីករណ្ដៅដាំគួររកឈើវែង ២ ហត្ថ ១ ចំអាម ទទឹង ៣ ធ្នាប់ កម្រាស់ កន្ទះធ្នាប់ ដាប់ឲ្យមានស្នាម លាក់ចុងដើមទឹងត្រង់កណ្ដាល ហើយតាប ទឹងបង្គោលដែលដើមឈើដាំដុះឡើងមកទទួលគ្នា ហើយបោះបង្គោល ត្រង់កន្ទ្រងជាប់ចុងដើមទាំងពីរនោះ កាលបើបានជីករណ្ដៅហើយទឹងមិន មានបង្គោលកណ្ដាលនៅតែបង្គោលសងខាង ។ ការជីកដីគួរជីកដីលើ ដែលមានពណ៌ចាស់ជាងដីក្រោមគរទុកដោយឡែក ហើយដីក្រោមក៏ ត្រូវគរទុកដោយឡែក ទុករណ្ដៅទទេហាលថ្ងៃប្រមាណ ២ អាទិត្យ ។

៨ – ការដាក់ជីមុនដាំ — ហេតុដែលដើមឈើចាប់ដុះលូតលាស់ ទឹងមានផ្លែផ្កាឆាប់រហ័សនៅត្រង់ការជីករណ្ដៅឲ្យជ្រៅហើយធំទឹងដាក់ ជីទុកពោលក្នុងរណ្ដៅនេះឯង គួររកជីអាចម៍សត្វឬជីស្លឹកឈើព្រៃឬស្មៅ ដាក់លាយទឹងដីនៅបាតរណ្ដៅ បានកន្ទះរណ្ដៅជាមុនសិន ។

៩ – ការចាប់ផ្ដើមដាំ — កាលបើបានដាក់ជីរៀបរយហើយឲ្យយក ឈើលាក់នោះមកតាបទឹងបង្គោលទាំងសងខាង ស្នាមលាក់ត្រង់កណ្ដាល ឲ្យនៅចំកណ្ដាលរណ្ដៅ ហើយសឹមយកដើមដំណាំដាំទៅដាក់ឲ្យចំ កណ្ដាលរណ្ដៅ ឲ្យដើមនៅត្រង់ស្នាមលាក់កណ្ដាល ទើបរាចដីកប់ឲ្យ ណែនទឹងរៀបរយទើបទុកជាស្រេចពិធីដាំ បើធ្វើដូច្នេះគ្រប់ៗដើម ដើម ឈើដំណាំទឹងមានជួរឬជួររៀបរយទឹងមានរយៈស្មើគ្នាទាំងអស់ ។

១០ – ការថែរក្សាក្រោយពេលបានដាំ — កាលបើដាំហើយមិនមានភ្លៀងធ្លាក់ទេ តោងស្វាហាប់ស្រោចទឹកជានិច្ច និងជីកជ្រួយដីក្បែរគល់ឲ្យស្រួលជានិច្ច ឬនឹងយកចំបើងគ្របគល់ក៏បាន ប្រយ័ត្នកុំឲ្យទឹកភ្លៀងដក់ខាំងជាប់ក្បែរគល់យូរពេក ។

២ – វិធីថែរក្សាចំការ – ការធ្វើចំការឲ្យបានផលចំរើនល្អនោះ លុះតែអ្នកចំការតោងខំធ្វើការងារជានិច្ច មិនមែនគ្រាន់តែដាំរួចទុកជាស្រេចទេ តោងខំថែរក្សាចំការដូចខាងតទៅនេះ គឺ:

(១) កាលដើមឈើនៅតូចមិនទាន់មានផ្លែផ្កា គួរជីកកាប់ដីឬភ្ជួររាស់ចន្លោះជួរដើមដំណាំរាល់ៗឆ្នាំ ហើយដាំបន្លែផ្សេងៗ ដូចជាសណ្ដែកដី ត្រាវ ដំឡូង ស្ពៃ ដីរ ឬអ្វីៗដទៃទៀតដែលឃើញថាល្មមដាំជ្រែកទៅបាន តែតោងប្រយ័ត្នកុំឲ្យដំណាំជ្រែកនេះទៅគ្របបាំងដើមឈើធំៗបាន ព្រោះអាចនាំឲ្យដើមដំណាំក្រឆាត់ធំចំរើន ។ ឯការដាំដំណាំជ្រែកក្នុងចន្លោះដើមដំណាំធំៗនេះនឹងមានប្រយោជន៍ដល់ ៣ ប្រការ គឺនាំឲ្យបានដំរះស្មៅនិងជ្រួយដីដើម្បីឲ្យដើមដំណាំធំ ១ នាំឲ្យបានផលប្រយោជន៍អំពីដំណាំជ្រែក ១ កាលដែលជីកដីជ្រួយដីឬភ្ជួររាស់ដើមស្លឹកបន្លែកប់ទៅក្នុងដីទៅ នាំឲ្យមានជីជាតិជាប្រយោជន៍ដល់ដើមដំណាំ ១ ។

(២) ដើមដំណាំចំពួកខ្លះមិនដុះលូតលាស់ល្អ ដោយត្រូវកំដៅថ្ងៃ ឬខ្យល់ព្យុះខ្លាំង ដូច្នេះគួរដាំដើមឈើឯទៀតបាំងថ្ងៃបាំងខ្យល់ផង ដើម

ឈើដែលគួរដាំបាំងខ្យល់នេះគឺដើមល្ហុស គួរដាំក្បែរខាងសម្រាប់បាំងខ្យល់និងបាំងថ្ងៃ ព្រោះដើមល្ហុសជាពូជសណ្តែក ដុះឆាប់ធំ ស្លឹកដែលជ្រុះធ្លាក់ចុះមកមានជីជាតិល្អដល់ដំណាំក្នុងចំការផង ។

(៣) កាលបើដើមដំណាំធំហើយ គួរធ្វើដូចនេះ

(ក) គោងនិងសង្រ្គាប់ជម្រះស្មៅនិងឈើព្រៃទៀតកុំឲ្យដុះស្លុកក្នុងចំការបាន ការដាំបន្លែដែកក៏គោងឈប់ដាំដែរ ។

(ខ) គួរថែរក្សាចំការឲ្យស្អាតជានិច្ច ស្លឹកឈើនិងស្មៅគួរជីករណ្តៅធ្វើជាអណ្តូងជីនៅក្បែរចំការ ដាក់ស្លឹកឈើស្មៅសម្រាមស្អុយរលួយ ហើយទុកប្រើធ្វើជីតទៅទៀត ។

(គ) ដើមដំណាំ ដើមណាមានផ្កាផ្លែតែមានខ្នាតតូចៗពេក ក៏គោងបេះផ្លែផ្កាចោលកុំឲ្យមានផ្លែជាប់នៅបានឬនឹងទុកផ្លែឲ្យរស់ ក៏គោងតែទុកឲ្យរស់តែបន្តិចបន្តួច បើទុកឲ្យមានផ្លែច្រើនពេកទៅនឹងធ្វើដើមឲ្យឆាប់ទ្រុឌទ្រោមឆាប់ឆាយ ទុកជាដើមធំឆាប់មានផ្កាផ្លែហើយក៏ដោយ បើមានផ្លែច្រើនក៏ត្រូវតែបេះផ្លែតូចៗចោលខ្លះដែរ ទុកតែល្មមសមគួរទើបមានផ្លែធំល្អនិងមានផ្លែច្រើន ។

(ឃ) ដើមឈើដែលដាំសម្រាប់បាំងជាម្លប់ដើមដំណាំ ដូចជាដើមល្ហុសនោះ កាលបើឃើញថាដើមដំណាំផុតពីអន្តរាយដោយកំដៅថ្ងៃនឹង

ខ្យល់ព្យុះហើយ ក៏គួរកាប់ដកចាស់ចេញ បើបណ្ដោយទុកយូរទៅក៏ទំនង ដណ្ដើមអាហារគេផងអាកាសពន្លឺពីដើមដំណាំ ធ្វើឲ្យដំណាំមិនល្អ បើត្រូវការទុកខ្លះក៏គួរទុកតាមរំមរបងតែបន្តិចបន្តួច ។

(ង) ការកាត់តែង — ដើមដំណាំណាដែលមានមែកធាងដុះចេញច្រើនពេក ឬមែកធាងច្រងេងច្រងាង ក៏គួរកាត់ចោលចេញខ្លះដែរ ហើយគួរកាត់មែកដែលបាក់ឬស្អុយចោលចេញ ត្រូវយករណារអារឲ្យជិតទងដើមឲ្យស្អាត យកប្រេងម៉ាស៊ីនឬយកកក់លាបក៏បាន ។

(ច) តោងដាក់ជីទីងជ្រួយដីយ៉ាងតិច ១ ឆ្នាំម្ដង គឺជិតផុតរដូវភ្លៀង គួរជីកជ្រួយដីទាំងចំការហើយយកដីមកលុបបង្កប់ជីឲ្យសព្វ ជាជីអាចម៍សត្វឬជីបន្លែស្លឹកឈើស្អុយក៏បាន ជីដែះទឹងជីផ្សឹងជារបស់ខានពុំបានសម្រាប់ដំណាំចំការ ។

(ឆ) បើដើមដំណាំមានកេតមានសត្វអ៊ុំៗ បៀតបៀនធ្វើឲ្យអន្តរាយផល់ដើមឈើឬផ្លែឈើ តោងប្រញាប់កំចាត់ចោលចេញតាំងពីកំមានចំនួនតិច បើបណ្ដោយទុកឲ្យរាលដាលច្រើនឡើងទើបកំចាត់ចេញនាំឲ្យលំបាកថែរក្សាជាអនេក ។

(ឈ) ការរកចំណេញខាងក្រៅ — ក្រៅពីការលក់ផ្លែឈើ អ្នកចំការគួរធ្វើកសិកម្មយ៉ាងដទៃទៀតប្រកបផង ដើម្បីជាកំរៃក្រៅដោយឡែកផ្សេងដូចជា

(ក) ការផ្សាំមែកឈើ — កូនរដូវក្មេងគួរហាត់ការផ្សាំដើមឈើផ្សេងៗ ទុកធ្វើពូជទំនើបដើមផ្កាខ្លះដាំក៏បាន ឬទំនងលក់យកចំណេញកំរៃដោយឡែកផ្សេងទៀតក៏បាន ។

(ខ) ការធ្វើចំការបន្លែ — អ្នកចំការគួរមានទីដីទំនេរខ្លះទុកដាំបន្លែសម្រាប់ជាប្រយោជន៍ដាំស្លក្នុងផ្ទះ ឬសល់លក់ជាអម្រែសអម្រែកក៏បាន ។

(គ) ការចិញ្ចឹមត្រី — អ្នកចំការបើមានស្រះឬមានអណ្តូងរបស់ខ្លួនសម្រាប់ចិញ្ចឹមត្រីទុកទទួលទាន ក៏ជាការដកសោហ៊ុយចាយយកបើថ្លៃត្រីបានច្រើនដែរ ក្រៅពីនេះយើងអាចដាំត្រកួន កញ្ឆែត ព្រលិតជាបន្លែអន្ទក់បានទៀតផង ។

(ឃ) ការចិញ្ចឹមមាន់ទីងជ្រូក- ក្នុងចំការប្រើថ្លៃជាវិសេសគួរទើងចិញ្ចឹមមាន់ទីងជ្រូក ព្រោះក្រៅពីបានប្រយោជន៍អំពីសាច់វានៅមានប្រយោជន៍ដោយឡែកទៀត ដូចជាអាចម៍វាជុះចុះក្នុងទីចំការទៅជាដីជល់ដើមដំណាំអស់នោះ ហើយមាន់ជាសត្វដែលចូលចិត្តចឹកដង្កូវទើងសត្វល្អិតដែលជាសត្រូវនឹងដើមដំណាំធ្វើជាអាហារវាផង ។ ឯជ្រូក យើងគោងធ្វើទ្រុងឬក្រោល កុំឲ្យវាដើរធ្វើអន្តរាយដល់ដើមដំណាំ សាច់ជ្រូកជារបស់មានតម្លៃហើយលក់ដាច់ជានិច្ចមិនដែលសល់ ក្រៅពីនេះអាចម៍ជ្រូក

ក៏មានប្រយោជន៍ធ្វើជីល្អដែរ ។ ឯកាកអាហារនិងកាកផ្លែឈើ កាកបន្លែ ចំពួកខ្លះមិនគួរយកទៅចាក់ចោលទេ គួរទុកធ្វើជាអាហាររបស់ជ្រូក ។

ប្រសិនបើអ្នកចំការចេះធ្វើចំការឬសួនតាមរបៀបដែលបានពោលមកនេះ ល្មមមានសង្ឃឹមថានឹងបានសេចក្ដីចំរើនមិនខាន ។

អ្នកចំការម្នាក់

# រឿងឈ្មួញម្នាក់

មាននិទានមួយដំណាលថា មានបុរសម្នាក់ទៅជួញមានដើមទុនតែហ្លួងមួយបានចំណេញមួយពាន់ដម្លឹង ហើយមានបុរសកំសត់ម្នាក់ក្នុងមួយថ្ងៃបរិភោគបាយតែម្តង ហើយមានសំពត់ស្លៀកតែមួយចង្កេះ ។ មានកាលថ្ងៃមួយ បុរសនោះស្លៀកសំពត់ហើយដើរទៅប្របមាត់ស្ទឹង ឯបុរសជួញបានប្រាក់មួយពាន់ក៏ពុនប្រាក់នឹងបាយសំណុំនឹងដំបងមួយដើរទៅដល់មាត់ស្ទឹងនឹងឆ្លង គ្រានោះទឹកជន់ឆ្លងពុំរួច ទើបបុរសនោះពោលឡើងថា មិត្តបម្លងអញផងអញឲ្យឈ្នួលមិត្តឯង ឯបុរសកំសត់ថា អញមិនបម្លងទៅទេ អញស្តាយសំពត់អញខ្លាចវាទទឹក ។ បុរសកែប្រាក់នោះស្រដីលោមថា មិត្តអើយ បើមិត្តបម្លងអញ ៗនឹងឲ្យឈ្នួលជាទ្រព្យសម្ងាត់ពេញចិត្ត ទើបបុរសកំសត់ព្រមបម្លងបុរសកែប្រាក់រួចដល់ត្រើយហើយ ក៏ទារឈ្នួលថា ឯណាមិត្តថាឲ្យទ្រព្យសម្ងាត់ពេញចិត្តអញ បុរសកែប្រាក់ថា មានតែបាយនេះឯងជាទ្រព្យសម្ងាត់ ៗ បុរសកំសត់ឆ្លើយថា ហៅមកនឹងអញថានឹងឲ្យទ្រព្យសម្ងាត់ដល់អញទើបអញបម្លងទៅ ដ្បិតអញពុំដែលបានសំពត់ស្លៀកអញខ្លាចទទឹកសំពត់អញ កាលបើឈ្លោះក្តី ហៅទាំងពីរក៏នាំគ្នាទៅប្តឹងដល់ចៅក្រមៗជំនុំថា បាយនោះជាទ្រព្យសម្ងាត់របស់គេ គួរហៅយកបាយនោះទៅអេះ ៗ ឯបុរស

កំសត់នោះពុំទទួលយកបាយ ទើបបុរសទាំងពីរនាំគ្នាទៅក្រាបទូលសម្តេចព្រះមហាក្សត្រាធិរាជ ព្រះអង្គបានជ្រាបដោយដំណើរនោះសព្វគ្រប់ហើយមានព្រះបន្ទូលថា បាយនោះទុកជាទ្រព្យសម្លាញ់ ហេតុអ្វីក៏ព្រះស្តេចមិនព្រមយកបាយ ។ បុរសកំសត់ក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំនឹងសុំយំ ទើបព្រះអង្គមានព្រះបន្ទូលថា ហេតុអ្វីក៏ព្រះស្តេចសុំយំ សូមទ្រង់ព្រះមេត្តាប្រោសដ្បិតទូលព្រះបង្គំជាខ្ញុំឆ្ងាយ ទើបព្រះអង្គមានព្រះបន្ទូលថា បើព្រះស្តេចចង់យំក៏យំតាមចិត្តព្រះស្តេចចុះ ទើបបុរសនោះយំខ្លូៗឮទៅដល់សម្តេចព្រះវររាជមាតា មានព្រះសវនីយ៍ដណ្តឹងសួរថាបុរសនោះយំថ្វី ទើបមានគេក្រាបទូលថា បុរសម្នាក់នោះថាគេនឹងឲ្យទ្រព្យសម្លាញ់ក៏ ឥឡូវនេះគេពុំឲ្យក៏ឡើយគេឲ្យឯបាយវិញ ទើបព្រះវររាជមាតាឲ្យទៅទូលសូមសេចក្តីអំពីសម្តេចព្រះរាជបុត្រនោះមកនឹងទ្រង់ពិចារណា ។ ឯសម្តេចព្រះរាជបុត្របើកសេចក្តីនោះថ្វាយទៅសម្តេចព្រះវររាជមាតា សម្តេចមានព្រះសវនីយ៍ត្រាស់ដណ្តឹងសួរបុរសទាំងពីរថា ហេតុអ្វីក៏ព្រះស្តេចកើតក្តីនឹងគ្នា បុរសទាំងពីរនោះក្រាបទូលដោយដំណើរទីទៃៗ ស្រេចហើយ ទើបសម្តេចមានព្រះសវនីយ៍ទៅកាន់បុរសវរកប្រាប់ថា នែព្រះស្តេច បើទ្រព្យឯណាជាទីស្រឡាញ់ពេញចិត្តព្រះស្តេចចូរយកទៅ ទ្រព្យឯណាព្រះស្តេចមិនស្រឡាញ់ចូរទុកនៅទីនោះចុះ

ទើបបុរសក្រោកឡើងដើរទៅយកតែសំពាយប្រាក់ ឯដម្បងទឹងបាយទុកទៅទីនោះ ទើបសម្តេចមានព្រះសវនីយ៍ថា អញប្រើព្រះស្តេចឲ្យយកទ្រព្យសម្បាញ់ ហេតុដូចម្តេចក៏ព្រះស្តេចពុំយកបាយទឹងដំបងទៅផង ក៏ព្រះស្តេចយកតែប្រាក់ទៅ បើដូច្នេះអញយល់ថាព្រះស្តេចថាប្រាក់នេះឯងជាទ្រព្យសម្បាញ់ពេញចិត្តហៅ ចូរទៅយកប្រាក់នោះមកអញៗ បែងជាភាគចែកទៅទាំងពីរឲ្យសុខចិត្តព្រមផងគ្នា កុំឲ្យវិវាទទៅវិញទៅមកឡើយ ទើបសម្តេចយកប្រាក់នោះមកចែកជាភាគបី ភាគមួយបានទៅម្ចាស់ទ្រព្យ ភាគពីរឲ្យបានទៅចៅចម្ងង់នោះ ឯចៅទាំងពីរចូលចិត្តព្រមព្រៀងគ្នាហើយក្រាបលាទៅកាន់លំនៅទីទៃៗហោង ។